01635453

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D382/26

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

ចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ិយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 01 / 2020
ម៉ោង (Time/Heure) : 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMN RADA

សាធារណៈ

# សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤

**សហព្រះរាជអាជ្ញា**

ជា លាង
**Brenda J. HOLLIS**

**សហមេធាវីការពារក្តីអ្នកដាក់ពាក្យសុំ**

សូ មូស្សេឌ្ឋី
**Suzana TOMANOVIĆ**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARTI



អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ"[១] ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ និង "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ចម្លើយតបទៅនឹងការឆ្លើយតបរបស់ខ្លួនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤"[២] ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ (រួមគ្នាហៅថា "សំណើ")។

១. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ដាច់ដោយឡែកពីគ្នា នៅក្នុងសំណុំរឿង ០០៤។ ខណៈដែលសហចៅក្រមស៊ើបអង្កេតជាតិបានចេញ "ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ" ("ដីកាលើកលែងចោទប្រកាន់")[៣] ជាភាសាខ្មែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ "ដីកាដំណោះស្រាយ"[៤] ជាភាសាអង់គ្លេស (រួមគ្នាហៅថា "ដីកាដំណោះស្រាយ")។

២. ការបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជាភាសាខ្មែរ ត្រូវបានដាក់នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ និងបានជូនដំណឹងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩។ ការបកប្រែដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេស ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។

៣. នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យផ្អាកកាលបរិច្ឆេទកំណត់សម្រាប់ភាគីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ រហូតដល់

[១] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 និង D382/23។

[២] សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ចម្លើយតបទៅនឹងការឆ្លើយតបរបស់ខ្លួន ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/22 និង D382/24។

[៣] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[៤] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

ពេលមានការជូនដំណឹងពីអង្គភាពបកប្រែភាសា អំពីសំណៅបកប្រែដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេសដែលបានកែតម្រូវរួច[៥]។

៤. សំណៅបកប្រែដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេសដែលបានកែតម្រូវរួច ត្រូវបានដាក់ និងជូនដំណឹង នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។

៥. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យភាគីដាក់សារណាបណ្តឹងឧទ្ធរណ៍ចំនួន ១០០ ទំព័រ ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីសំណៅបកប្រែដីកាសម្រេចលើកលែងចោទប្រកាន់ជាភាសាអង់គ្លេសដែលបានកែតម្រូវរួច នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩[៦]។

៦. នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៧] ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ") ជាភាសាខ្មែរ។ ការបកប្រែបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិជាភាសាអង់គ្លេស ត្រូវបានជូនដំណឹងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិជាភាសាអង់គ្លេស។ ការបកប្រែចម្លើយតបជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។

---

[៥] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាឲ្យផ្តល់នូវការបកប្រែដោយត្រឹមត្រូវជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/12 និង D382/13។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឲ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ដែលត្រឹមត្រូវ និង ផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/5 និង D382/5។ សំណុំរឿង ០០៤ អ៊ីម៉ែលរបស់ការិយាល័យសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការបកប្រែដីកាលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤ (D381) ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/6។

[៦] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និង D382/19។

[៧] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទិននឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1។

01635456



៧. សហមេធាវីការពារក្តី យឹម ទិត្យ ("សហមេធាវី") បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ នៅក្នុងសំណុំរឿង ០០៤[៨] នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៩] នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ទាំងពីរត្រូវបានដាក់ជាភាសាអង់គ្លេសតែមួយភាសា។ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ")[១០] ជាភាសាអង់គ្លេស។ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ ("បណ្តឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី")[១១] ជាភាសាអង់គ្លេស និងភាសាខ្មែរ (រួមគ្នាហៅថា "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ")។

៨. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីបានដាក់សំណើបន្ទាន់សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ដោយស្នើសុំការអនុញ្ញាតពីអង្គបុរេជំនុំជម្រះឲ្យសហមេធាវីដាក់ (១) ចម្លើយតបចំនួន ៥០ ទំព័រទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងចម្លើយតបចំនួន ៣០ ទំព័រទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីការបកប្រែបណ្តឹងឧទ្ធរណ៍ទាំងពីរ (២) ការឆ្លើយតបចំនួន ៣០ ទំព័រទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរយៈពេល ២៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីចម្លើយតបទាំងអស់ និង (៣) ចម្លើយតប និងការឆ្លើយតបជាភាសា

[៨] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ទៅនឹងការចេញដីកាដំណោះស្រាយពីរនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 និង D382/21។

[៩] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ទៅនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសំណុំរឿង ០០៤ ឯកសារ D382/22។

[១០] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19។

[១១] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20។

01635457



អង់គ្លេសតែមួយភាសាសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់បំផុត[១២]។

៩. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតប និងការឆ្លើយតបរបស់ខ្លួន ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ដោយស្នើសុំការអនុញ្ញាតពីអង្គបុរេជំនុំជម្រះដើម្បីដាក់ (១) ចម្លើយតបចំនួន ៨០ ទំព័រទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងរយៈពេល ៤០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីការបកប្រែបណ្តឹងឧទ្ធរណ៍ (២) ការឆ្លើយតបទៅនឹងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ ក្នុងរយៈពេល ២៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីចម្លើយតបទាំងអស់ និង (៣) ចម្លើយតប និងការឆ្លើយតបជាភាសាអង់គ្លេសតែមួយភាសាសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់បំផុត។

១០. នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងសំណើបន្ទាន់របស់សហមេធាវី ដោយលើកឡើងថា គាត់មិនជំទាស់ទៅនឹងសំណើទេ[១៣]។

១១. អនុលោមតាមវិធាន ៣៩(២) និង (៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់ និង/ឬពន្យារពេលវេលាកំណត់សម្រាប់ដាក់ឯកសារពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍។ អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ អង្គជំនុំជម្រះក៏អាចបន្ថែមចំនួនទំព័រឯកសារបានដែរ នៅក្នុងកាលៈទេសៈពិសេស។

១២. អង្គបុរេជំនុំជម្រះកត់សម្គាល់អំពីទំហំ និងភាពស្មុគស្មាញនៃបណ្តឹងឧទ្ធរណ៍ ទាក់ទិននឹងវិសាលភាព និងភាពធំធេងនៃបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនោះ ព្រមទាំងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការរក្សាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះ

---

[១២] សំណុំរឿង ០០៤ សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 និង D382/23។

[១៣] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់របស់ យឹម ទិត្យ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/23 និង D382/25។

ដោយយុត្តិធម៌ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា វាជាការចាំបាច់ដែលត្រូវអនុញ្ញាតឱ្យភាគីទាំងអស់ទទួលបានពេលវេលា និងចំនួនទំព័របន្ថែមសមស្រប ដើម្បីដាក់ចម្លើយតប និងការឆ្លើយតបរបស់ខ្លួន។

១៣. ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា គុណភាព និងប្រសិទ្ធភាពនៃសារណាបណ្តឹងឧទ្ធរណ៍ពុំមែនអាស្រ័យទៅលើទំហំរបស់វាទេ តែផ្ទុយទៅវិញគឺអាស្រ័យទៅលើភាពច្បាស់លាស់ និងភាពសមហេតុផលនៃទឡ្ហីករណ៍ដែលបានដាក់បង្ហាញ ហេតុនេះហើយសារណាដែលវែងហួសហេតុពុំបានជួយសម្រួលដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះយ៉ាងមានប្រសិទ្ធភាពឡើយ[១៤]។

១៤. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងរក្សាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងប្រសិទ្ធភាពនោះ ជាការត្រឹមត្រូវក្នុងការបន្ថែមទំព័រចំនួន ៣០ ទំព័រ និងពេលវេលាកំណត់ចំនួន ៣៥ ថ្ងៃថែមទៀតដល់ភាគីទាំងអស់ ដើម្បីដាក់ចម្លើយតបរបស់ខ្លួន និងបន្ថែមពេលវេលាកំណត់ចំនួន ២០ ថ្ងៃថែមទៀតដើម្បីដាក់ការឆ្លើយតប ដោយចាប់គិតពីពេលជូនដំណឹងពីការបកប្រែបណ្តឹងឧទ្ធរណ៍នីមួយៗ និងចម្លើយតបនីមួយៗ។ អង្គជំនុំជម្រះនឹងពុំអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ថែមទៀតឡើយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយក** ផ្នែកខ្លះនៃសំណើ។

**អនុញ្ញាត**ឱ្យភាគីដាក់ចម្លើយតបចំនួន ៦០ ទំព័រ ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីការបកប្រែបណ្តឹងឧទ្ធរណ៍នីមួយៗ។

**អនុញ្ញាត**ឱ្យភាគីដាក់ការឆ្លើយតបចំនួន ៣០ ទំព័រ ក្នុងរយៈពេល ២៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីការបកប្រែចម្លើយតបនីមួយៗ។

---

[១៤] *សូមមើល* យន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (MICT) *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A សេចក្តីសម្រេចទៅលើសំណើសុំបង្កើនចំនួនអក្សរកំណត់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ២។

01635459



**អនុញ្ញាត**ឱ្យភាគីដាក់ចម្លើយ និងការឆ្លើយតបមួយភាសាសិន ចំណែកការបកប្រែនឹងដាក់ជូនតាមក្រោយ។

**ណែនាំ**ឱ្យអង្គភាពបកប្រែភាសាត្រូវធានាថា ការបកប្រែដែលបានស្នើសុំ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ២០ ថ្ងៃ ចាប់ពីថ្ងៃដាក់ចម្លើយតប និង ១៥ ថ្ងៃ ចាប់ពីថ្ងៃដាក់ការឆ្លើយតប។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គិមសាន** **Olivier BEAUVALLET** **នេយ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**